# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្ងានៅកោះទាច
# ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៨
## *ខ្ញុំចាត់ទុកអ្នករាល់គ្នាជាមិត្តសម្លាញ់*

អត្ថបទទី១៖ កក ១០,២៥-២៦.៣៤-៣៥.៤៤-៤៨
អត្ថបទទី២៖ ១យហ ៤,៧-១០
ដំណឹងល្អ៖ យហ ១៥,៩-១៧

បងប្អូនជាទីស្រឡាញ់!

នៅថ្ងៃនេះយើងអានអត្ថបទទី២ ជាអត្ថបទមួយដែលណែនាំឲ្យយើងស្គាល់ព្រះជាម្ចាស់ជានរណា? ព្រះបន្ទូលនេះគឺ "**ដ្បិតព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់**"។ នៅក្នុងគម្ពីរតាំងពីកំណើតពិភពលោករហូតដល់ថ្ងៃចុងក្រោយនៃពិភពលោក យើងឃើញនិយាយពីព្រះជាម្ចាស់ច្រើន "**ព្រះជាម្ចាស់ដែលជាម្ចាស់ជីវិត ព្រះជាម្ចាស់ដែលជាព្រះបិតា ព្រះជាម្ចាស់ដែលបានបង្កើតពិភពលោក ព្រះជាម្ចាស់ដែលបានធ្វើដំណើរជាមួយប្រជារាស្ដ្រអ៊ីស្រាអែល ព្រះជាម្ចាស់ដែលបានចាត់ឲ្យព្រះយេស៊ូ ចាប់កំណើតជាមនុស្ស**"។ ប៉ុន្ដែ នៅក្នុងលិខិតរបស់លោកយ៉ូហាន យើងមានតែម្ដងគត់ដែលថា **ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់**។ នៅពេលយើងថាព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ គឺសរុបទាំងអស់ចាប់តាំងពីដើមរៀងមករហូតដល់ពេលនេះ។

កុំឲ្យយើងយល់ច្រឡំ មិនមែនតែព្រះជាម្ចាស់ស្រឡាញ់យើង មិនមែនតែព្រះជាម្ចាស់អាណិតអាសូដល់យើង គឺព្រះជាម្ចាស់ផ្ទាល់ជាសេចក្ដីស្រឡាញ់ពិតមែន។ ហេតុនេះហើយ យើងអាចនិយាយអំពីយើង យើងស្រឡាញ់គេ យើងស្អប់គេ យើងបង្កើតទំនាក់ទំនងជាមួយគេ យើងលើកលែងទោសឲ្យគេ យើងជាមនុស្សជាបុរស ជាស្ដ្រី ប៉ុន្ដែថ្ងៃនេះយើងបានស្ដាប់អំពីលក្ខណៈរបស់ព្រះជាម្ចាស់គឺ "**ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់**"។ ដោយសារព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ ព្រះអង្គចង់ឲ្យយើងទាំងអស់មានជីវិត មានសុភមង្គល និងជាពិសេសឲ្យយើងទាំងអស់ទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដែលរស់នៅក្នុងសេចក្ដីស្រឡាញ់។

នៅថ្ងៃនេះ យើងស្ដាប់ព្រះយេស៊ូ ដែលកំពុងនិយាយជាមួយក្រុមគ្រីស្ដទូត មុនព្រះយេស៊ូសោយព្រះទិវង្គត។ យើងដឹងហើយនៅពេលមនុស្សម្នាក់និយាយដល់កូនចៅ ឧទាហរណ៍លោកតា លោកយាយកំពុងឈឺយ៉ាងខ្លាំង គាត់ហៅបងប្អូននិងកូនចៅឬកូន ដើម្បីនិយាយដល់ពេលវេលាចុងក្រោយ គឺជាពេលវេលាមួយពិសេសដើម្បីចែករំលែកមរតកដ៏សំខាន់បំផុត។ ថ្ងៃនេះដែលយើងទទួលអគ្គសញ្ញាលាបថ្ងាស និងជាពេលវេលាដែលព្រះយេស៊ូមានរឿងមួយដ៏សំខាន់ ដោយសារព្រះយេស៊ូនិយាយដល់ក្រុមគ្រីស្ដទូត ក៏ដូចជានិយាយដល់យើងដែរ នេះសំខាន់ណា

ស់។ នៅក្នុងរឿងសំខាន់បំផុត ដែលព្រះយេស៊ូចង់និយាយមុនសោយព្រះទិវង្គត ទុកជាមរតកសំខាន់បំផុតសម្រាប់ជីវិតរបស់យើងគឺ "**វិន័យរបស់ខ្ញុំគឺអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**"។ នៅក្នុងសម្ព័ន្ធមេត្រីចាស់ គេមានវិន័យច្រើនណាស់ ជាង៦០០មាត្រា។ ប៉ុន្តែមុនព្រះយេស៊ូសោយព្រះទិវង្គត ព្រះយេស៊ូបានប្រគល់វិន័យតែមួយគត់ "**វិន័យរបស់ខ្ញុំគឺអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**"។

បងប្អូនជាគ្រីស្តបរិស័ទ បងប្អូនដែលត្រៀមខ្លួនទទួលអគ្គសញ្ញាលាបថ្ងាស សូមគិតធ្វើយ៉ាងដូចម្តេចដើម្បីស្រឡាញ់ដូចព្រះយេស៊ូស្រឡាញ់? ដើម្បីជួយយើង យើងមានព្រះយេស៊ូដោយសារព្រះយេស៊ូបានបន្ថែមថា "**ខ្ញុំចាត់ទុកអ្នករាល់គ្នាជាមិត្តសម្លាញ់**" ព្រះយេស៊ូបានចាត់ទុកយើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ។ ព្រះយេស៊ូមិនមែនមេយើង ដែលយើងជាអ្នកបម្រើព្រះអង្គព្រះយេស៊ូមិនមែនជាមេដែលគ្រប់គ្រងយើង ប៉ុន្តែព្រះយេស៊ូជ្រើសរើសយើងដើម្បីធ្វើជាមិត្តសម្លាញ់របស់ព្រះយេស៊ូ។ ជឿថាក្មេងៗមានមិត្តសម្លាញ់ មានពួកម៉ាកច្រើន សប្បាយចិត្តដើរលេងជាមួយគ្នា សប្បាយចិត្តចែករំលែកឲ្យគ្នាទៅវិញទៅមក ប៉ុន្តែថ្ងៃនេះយើងមានមិត្តពិសេសបំផុត គឺ ព្រះយេស៊ូផ្ទាល់។ ហេតុនេះហើយ ថ្ងៃនេះយើងពោរពេញដោយអំណរសប្បាយ និងកម្លាំង ដោយសារព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ ព្រះយេស៊ូណែនាំឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូ។ ដើម្បីស្រឡាញ់ដូចព្រះយេស៊ូ យើងមានគំរូមួយពិសេសគឺមិត្តសម្លាញ់ពិសេសដែលណែនាំយើង។ ដូចយើងដឹងស្រាប់ហើយមិត្តល្អណែនាំឲ្យល្អ មិត្តមិនល្អណែនាំឲ្យយើងមិនល្អ។ ថ្ងៃនេះយើងមានព្រះយេស៊ូដែលជាមិត្តពិសេសដល់កំពូល ដែលណែនាំឲ្យយើងស្គាល់ព្រះបិតាតែម្តង។

ថ្ងៃនេះជាថ្ងៃពិសេស នៅក្នុងអត្ថបទទីមួយ "**ព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមកសណ្ឋិតលើអ្នករាល់គ្នា ដែលស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់**"។ យើងមានអ្នកដែលស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូ យើងមានមិត្តសម្លាញ់ជាព្រះយេស៊ូផ្ទាល់ និងយើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីអនុវត្តន៍រស់នៅជាគ្រីស្តបរិស័ទរស់នៅយ៉ាងល្អ ដែលមានព្រះយេស៊ូជាមិត្តសម្លាញ់យ៉ាងជិតស្និទ្ធបំផុត។ ព្រះវិហារនេះបានលាបថ្នាំថ្មី ប៉ុន្តែបាត់រូបមួយនៅព្រះវិហារនេះ ពីមុនមានរូបមរណៈសាក្សីនៅវៀតណាម។ នៅឆ្នាំក្រោយ នៅប្រទេសវៀតណាមគេបើកឆ្នាំមហាករុណាទិគុណដើម្បីរំឭកដល់មរណៈសាក្សី១១៧នាក់ ដែលស្លាប់នៅប្រទេសវៀតណាម។ ខ្ញុំនិយាយពីមរណៈសាក្សី ដោយសារមរណៈសាក្សីនៅវៀតណាម នៅកម្ពុជា និងប្រទេសឡាវ ជាគំរូមួយដើម្បីមានកម្លាំងដោយមើលឃើញនូវជំនឿ ដោយយើងមានព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងទទួល ណែនាំឲ្យមានសេចក្តីក្លាហានប្រកាសថា ខ្ញុំជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ខ្ញុំមិនក្បត់ព្រះយេស៊ូ ខ្ញុំភ្ជាប់

ជាមួយព្រះយេស៊ូអស់មួយជីវិត ទោះបីខ្ញុំត្រូវបាត់បង់ជីវិតក៏ដោយ។ ដូច្នេះ បងប្អូនមិនចង់ធ្វើជាមរណៈសាក្សី តែយ៉ាងតិចសូមឲ្យយើងធ្វើជាសាក្សី។ មរណៈសាក្សី មានន័យថាយើងស្លាប់ ប្តូជាដូចព្រះយេស៊ូ ប៉ុន្តែយ៉ាងតិចឲ្យយើងធ្វើជាសាក្សីពីព្រះយេស៊ូ ដោយសារយើងជាមិត្តសម្លាញ់របស់ព្រះអង្គ ដែលសុខចិត្តប្តូរជីវិតសម្រាប់បងប្អូនឯទៀតៗ "**គ្មាននរណាមានសេចក្តីស្រឡាញ់ខ្លាំងជាងអ្នកដែលស៊ូប្តូរជីវិត ដើម្បីមិត្តសម្លាញ់របស់ខ្លួននោះឡើយ**"។

ខ្ញុំជូន៥ចំណុចដើម្បីទៅជាសាក្សីដ៏វិសុទ្ធ ដូចព្រះយេស៊ូជាមិត្តសម្លាញ់យើង៖

**ចំណុចទីមួយ ឲ្យយើងទៅជាមនុស្សដែលតស៊ូ ដែលមានចិត្តអត់ធ្មត់** នៅក្នុងជីវិតរបស់យើងជាមិត្តសម្លាញ់របស់ព្រះអង្គ។

**ចំណុចទីពីរ ឲ្យយើងទៅជាមនុស្សដែលពោរពេញដោយអំណរសប្បាយ** ដូចព្រះនាងម៉ារីទទួលដំណឹងពោរពេញដោយអំណរសប្បាយ ដូចសន្តសន្តី ដូចមរណៈសាក្សី ដូចគ្រីស្តបរិស័ទយ៉ាងច្រើន ទោះបីជាយើងទទួលទុក្ខលំបាកនៅក្នុងជីវិត យើងទទួលអំណរសប្បាយដ៏ពេញលក្ខណៈពីព្រះយេស៊ូ។

**ចំណុចទីបី ឲ្យយើងមានសេចក្តីក្លាហាន ដើម្បីប្រកាសជំនឿ**។ កុំឲ្យយើងខ្មាសអៀន កុំឲ្យយើងខ្លាច។ ឲ្យយើងពោរពេញដោយសេចក្តីក្លាហាន និងការទទួលខុសត្រូវជាពិសេសបេក្ខជនដែលទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៅថ្ងៃនេះ យើងទទួលខុសត្រូវដោយសារព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយើង ដើម្បីទៅបង្ហាញសេចក្តីស្រឡាញ់ បង្ហាញការលើកលែងទោស បង្ហាញចិត្តអាណិតមេត្តាតាមព្រះយេស៊ូដែរ យើងត្រូវការមានសេចក្តីក្លាហាន។

**ចំណុចទីបួន យើងជាគ្រីស្តបរិស័ទនៅក្នុងព្រះសហគមន៍** ឲ្យយើងយកចិត្តទុកដាក់ចូលនៅក្នុងវិហារ អធិដ្ឋាន បម្រើតាមក្រុមផ្សេងៗ។ កុំឲ្យយើងធ្វើជាយុវជនយុវនារី និងកូនក្មេងដែលថ្ងៃនេះទទួលអគ្គសញ្ញាលាបថ្វាស និងថ្ងៃស្អែកលែងចូលវិហារ។ យើងទទួលភាពដ៏វិសុទ្ធ យើងទទួលកម្លាំង យើងទទួលទំនាក់ទំនងនៅក្នុងមិត្តភាពរវាងព្រះយេស៊ូនិងយើង នៅក្នុងព្រះសហគមន៍។ ដូច្នេះសូមគិត នរណាចង់ធ្វើជាក្រុមយុវជន? នរណាចង់ធ្វើក្រុមកាយឫទ្ធិ? នរណាចូលក្រុមកងពលព្រះនាងម៉ារី និងក្រុមព្រះបេះដូងព្រះយេស៊ូ? នរណាចូលក្រុមចម្រៀង? នរណាជួយសម្អាតវិហារ? នរណាជួយក្រុមសង្គហៈដើម្បីជួយអ្នកក្រីក្រ? នរណាធ្វើក្រុមមោងសាយ? ប៉ុន្តែជួយនៅក្នុងព្រះសហគមន៍។

**ចំណុចទីប្រាំ ឲ្យយើងអធិដ្ឋានជានិច្ច** ប្រសិនបើយើងមិនអធិដ្ឋាន តើយើងជាប់ជាមួយព្រះជាម្ចាស់ទេ? ប្រសិនបើយើងមិនអធិដ្ឋាន យើងអត់មានទំនាក់ទំនងជាមួយព្រះយេស៊ូ។ នៅពេលដែលយើងអត់មានទំនាក់ទំនងជាមួយមិត្តសម្លាញ់របស់យើង យើងលែងស្គាល់គ្នាទៅវិញទៅមក អធិដ្ឋានជានិច្ចដើម្បីជិតស្និទ្ធជាមួយមិត្តសម្លាញ់យើង។

ជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដើម្បីជួបជាមួយព្រះជាម្ចាស់នៅពេលយើងទទួលមរណភាព។ ទោះបីយើងអត់ដឹងពេលណាដែលយើងទទួលមរណភាព ប៉ុន្តែយើងរៀបចំចាប់ពីពេលនេះទៅដើម្បីទទួលជីវិតអស់កល្បជានិច្ច។ យើងមានជួងនៅទីនេះ កុំឲ្យយើងភ្លេចបើកត្រចៀកដើម្បីស្តាប់ឮសំឡេងជួង ដែលហៅយើងឲ្យជួបជាមួយព្រះជាម្ចាស់។ នៅពេលយើងបានជួបជាមួយមិត្តសម្លាញ់របស់យើង កុំភ្លេចទៅផ្តល់សាក្សីភាពដល់មនុស្សឯទៀតៗ។ នេះជាព្រះវិញ្ញាណដ៏វិសុទ្ធផ្តល់កម្លាំងឲ្យយើង ដ្បិតព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ អាម៉ែន៕